

# កក់វ៉ាក់សាំងផ្តាសាយដោយឥតគិតថ្លៃរបស់អ្នកនៅថ្ងៃនេះ

## ចាក់វ៉ាក់សាំង

ជំងឺផ្តាសាយធំ (ផ្តាសាយ) ជាធម្មតាឡើងខ្ពស់បំផុតនៅ រដូវរងា ដូច្នេះយកល្អ អ្នកគួរតែចាក់វ៉ាក់សាំងបង្កាជំងឺផ្តាសាយមុនរដូវផ្តាសាយមកដល់។

អ្នកអាចចាក់វ៉ាក់សាំងពីគ្រូពេទ្យទូទៅក្នុងតំបន់របស់អ្នក ពីគ្លីនិកសុខភាពសហគមន៍ ឬពីឱសថស្ថាន។

វ៉ាក់សាំងនេះត្រូវបានណែនាំសម្រាប់មនុស្សដែលមានអាយុលើសពី 6 ខែឡើងទៅ។ អ្នកអាចទទួលថ្នាំបង្ការជំងឺផ្តាសាយដោយឥតគិតថ្លៃប្រសិនបើអ្នកពុំមានប័ណ្ណមេឌីឃែរ

ឲ្យតែអ្នករស់នៅក្នុងរដ្ឋឃ្វីនស្លែន។

## តើហេតុអ្វីបានជាវ៉ាក់សាំងមានសារៈសំខាន់?

ជំងឺផ្តាសាយធំគឺជាជំងឺឆ្លងខ្លាំងណាស់ដែលអាចធ្វើឲ្យប្រជាជនខ្លះឈឺធ្ងន់ធ្ងរ។ វាអាចធ្វើឲ្យមានភាពស្មុគ្រស្មាញធ្ងន់ធ្ងរ រួមទាំងការត្រូវទៅមន្ទីរពេទ្យ និងស្លាប់ផង។

ជនដែលមានហានិភ័យខ្ពស់បំផុតក្នុងការត្រូវទៅមន្ទីពេទ្យ គឺកុមារក្មេងៗ ជនវ័យចំណាស់ ស្ត្រីមានផ្ទៃពោះ ហើយនិងជនដែលមានជំងឺដូចជាទឹកនោមផ្អែម បញ្ហាសួតនិងបេះដូង។

វាជាការសំខាន់ណាស់ដែលគេត្រូវទប់ស្កាត់ជំងឺផ្តាសាយដោយធានាថា គ្រប់គ្នាចាក់ថ្នាំបង្ការនោះ ជាពិសេសអ្នកដែលមានហានិភ័យខ្ពស់ជាងគេ។

## ការចាក់ថ្នាំបង្ការសម្រាប់ប្រជាជនថ្មីនៅរដ្ឋឃ្វីនស្លែន

សម្រាប់អ្នកមកដល់ប្រទេសអូស្ត្រាលីថ្មី រដ្ឋាភិបាលសហព័ន្ធផ្តល់ជូនដោយឥតគិតថ្លៃនូវសេវាកម្មបកប្រែប័ណ្ណចាក់ថ្នាំបង្ការសម្រាប់ឆ្លងដែន និងឯកសារចាក់ថ្នាំបង្ការទាំងឡាយពីមុនៗផង។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលសេវាកម្មបកប្រែនៃក្រសួងមហាផ្ទៃ ឬទូរស័ព្ទទៅលេខ 1800 962 100 ។

## តើការចាក់ថ្នាំបង្ការជំងឺផ្តាសាយនេះត្រូវតាមក្បួនច្បាប់ Halal និង Kosher ឬទេ ?

ថ្នាំបង្ការទាំងឡាយត្រូវបានអនុញ្ញាតិសម្រាប់កុមារដែលគោរពសាសនាឥស្លាម (**Halal**) និងកុមារដែលគោរពសាសនាជ្វីហ្វ (Kosher)។

មានព័ត៏មានបន្ថែមនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានសម្រាប់សុវត្ថិភាពនៃថ្នាំបង្ការ (Institute for Vaccine Safety)។

## ត្រូវការព័ត៏មានបន្ថែមទៀតមែនទេ?

សូមពិភាក្សាជាមួយគ្រូពេទ្យទូទៅរបស់អ្នក ប្រសិនបើអ្នកមានសំណួរណាមួយអំពីការចាក់វ៉ាក់សាំងបង្កាជំងឺគ្រុនផ្តាសាយធំ។

អ្នកក៏អាចទូរសព្ទទៅកាន់ **13 HEALTH** តាមរយៈលេខ **13 43 25 84** ហើយនិយាយទៅកាន់គិលានុបដ្ឋាយិកា។

សូមស្នើសុំអ្នកបកប្រែ បើសិនជាអ្នកត្រូវការ។ អ្នកអាចស្វែងយល់បន្ថែមទៀតអំពីវ៉ាក់សាំងបង្កាជំងឺផ្តាសាយ

និងធនធាននានាជាភាសារបស់អ្នកនៅទីនេះ។